# គុណសម្បត្តិនៃអ្នកទេសនា

## ព្រះទេពសត្ថា សូរ ហាយ ក្រុមជំនុំព្រះត្រៃបិដក

## តែងរៀបរៀង

លោកអ្នកទេសនាឬអ្នកនិយាយត្រូវប្រកបដោយគុណសម្បត្តិអ្វីខ្លះ? នេះជាប្រស្នាដែលគួរឆ្លើយដោយពិស្តារ។ គុណសម្បត្តិរបស់លោកអ្នកទេសនាឬអ្នកនិយាយក្នុងទីប្រជុំធំតូចនីមួយៗមាន២ប្រការគឺៈ គុណសម្បត្តិសាមញ្ញ១ គុណសម្បត្តិជាន់ខ្ពស់១ ដូចសេចក្តីតទៅនេះ ៖

១–មាត់រហ័ស,

២–ចិត្តអង់អាច,

៣–ឥតអៀនខ្មាស,

៤–សម្លេងឮខ្លាំង។

គុណសម្បត្តិ៤យ៉ាងនេះ មនុស្សសាមញ្ញច្រើនទទួលដឹង ស្គាល់ និយមថា ជាគុណសម្បត្តិល្អម្យ៉ាងដែរហើយ តែមិនទាន់រាប់ថាជាគុណដ៏ប្រសើរខ្ពង់ខ្ពស់ទេ, បើគ្រាន់តែមានគុណសម្បត្តិសាមញ្ញ៤យ៉ាងប៉ុណ្ណោះ នឹងត្រឡប់ទៅជាទោសក្នុងការសម្តែងវិញខ្លះពុំខាន ព្រោះ ៖

មាត់រហ័ស គឺសម្តៅយកមាត់ដែលរួស ដែលនិយាយញាប់។ ការនិយាយរួសញាប់នេះ មិនមែនសុទ្ធតែជាគុណទាំងអស់ទេ រមែងធ្លាក់ទៅជាទោសវិញខ្លះជាធម្មតា គឺនាំឱ្យភ្លាត់ពាក្យពេចន៍, ឱ្យជ្រុលជ្រលួសពាក្យដែលគួរលើកនិយាយមុនត្រឡប់ទៅជានៅក្រោយ, ឯពាក្យដែលគួរដាក់ទៅខាងក្រោយត្រឡប់ទៅជាមុន។ ការនិយាយញាប់នេះជាទោសនាំឱ្យខូចរបៀបពាក្យរៀបរយ គឺនាំឱ្យកម្រងពាក្យក្នុងប្រយោគដែលនិយាយនោះមិនមានដើមសម្ព័ន្ធត្រឹមត្រូវទាំងស្រៈព្យញ្ជនៈ ដែលត្រូវប្រកបឱ្យច្បាស់លាស់តាមសម្លេងអក្សរក៏មិនពេញបរិបូណ៌ តែងខ្វះខាតខូចសម្លេងជ្រុងស្រៈព្យញ្ជនៈនោះជាដរាប។

ការនិយាយរហ័សនេះ បើបណ្តោយយូរៗទៅ ជាហេតុឱ្យធ្លាប់ធ្លាយប្រយោគនិយាយ នោះខូចសេចក្តីអស់ទៅក៏មាន ឱ្យពាក្យនោះរត់លឿនហួសគំនិត ទាល់តែ

ខ្លួនឯងក៏ស្តាប់មិនបានទៅក៏មាន។ ការដែលថ្នឹកនិយាយឲ្យបានញាប់ហើយឱ្យច្បាស់លាស់គ្រប់ម៉ាត់នេះ ជាការក្រណាស់ ច្រើនតែនាំឱ្យខូចរបៀបគ្រប់យ៉ាង ជួនកាលគ្រាន់តែញាប់មែន ប៉ុន្តែចេះតែជួនៗ សាំៗ ដដែលៗ មិនលឿនចំណេញទៅមុខសោះ តែបើអាចនិយាយបានទាំងរហ័ស ទាំងត្រឹមត្រូវក៏ជាការប្រសើរណាស់។ ត្រង់ពាក្យដែលគេធ្លាប់និយាយថា "សម្តីជាឯក លេខជាទោ" នោះ មិនមែនសម្តៅយកសម្តីញាប់ឡប់ៗនោះឡើយ គឺសម្តៅយកសម្តីដែលចេញទៅជាពាក្យមានរបៀបសណ្តាប់ធ្នាប់, មានបែបបទត្រូវតាមច្បាប់ទម្លាប់ ជាសម្តីដែលមានគំនិតដើរមុន ទើបមានសម្លេងចេញទៅជាខាងក្រោយ ហើយជាពាក្យមានគោលជាគ្រឿងអាង។

ចិត្តអង់អាច គឺចិត្តក្លៀវក្លា, មោះមុតមិនញាប់ញ័រ, មិនតក់ស្លុត។ ការនិយាយឬទេសនាដោយចិត្តអង់អាចនេះ ជួនកាលក៏មានអាការសមរម្យ ជួនកាលក៏មិនសមរម្យ ដែលគួរឲ្យអ្នកស្តាប់រិះគន់បាន។ ការនិយាយនេះ បើបណ្តោយឱ្យចិត្តអង់អាចនិយាយឡើងដោយការលុះក្នុងអំណាចរបស់ចិត្តអង់អាចនោះ ក៏ច្រើនតែហួសប្រមាណ នាំឱ្យខូចឱ្យខុសច្បាប់ ព្រោះអាងកម្លាំងសេចក្តីអង់អាចដែលនាំឱ្យភាន់ច្រឡំក៏មាន នាំឱ្យមានសេចក្តីប្រកាន់ខុសដោយអាងវោហារក៏មាន។

ការទេសនាឬនិយាយ ដែលលុះអំណាចចិត្តអង់អាចខ្លាំងហួសហេតុពេកនេះ ច្រើតែទៅជាទោស គឺនាំឲ្យភ្លាត់ភ្លាំងច្បាប់ទម្លាប់, នាំឱ្យភ្លេចគិតអំពីហេតុផល, អំពីការទើសទាក់ក្នុងច្បាប់ទាំងពួង ព្រោះហេតុនោះ ការនិយាយដោយកម្លាំងចិត្តអង់អាចហួសពេក មិនមែនសុទ្ធតែជាគុណទាំងអស់ទេ តែត្រឡប់ទៅជាទោសវិញខ្លះមិនខាន, មុនអំពីការទេសនាឬនិយាយ ត្រូវស្ទង់កម្លាំងចិត្តឱ្យល្មម, ត្រូវថ្នមចិត្តឱ្យនឹងធឹងល្អ ទើបនិយាយជាការប្រសើរ។ ព្រោះថាបើកម្លាំងចិត្តអង់អាចពេក លុះត្រូវនិយាយក៏ច្រើនតែប្រើវោហារហួសប្រមាណ ដែលគួរឱ្យគេរិះគន់ចាប់ផ្តាក់បាន។

ឥតអៀនខ្មាស គឺស្ទុះជនខាងនិយាយក្នុងកាលមិនគួរ។ ការទេសនាឬនិយាយប្រកបដោយសេចក្តីអៀនខ្មាសពេក ក៏សម្តែងមិនកើតដែរ តែបើបណ្តោយឱ្យឥតអៀនខ្មាសសោះក៏មិនកើត នឹងនាំឱ្យទៅជាទោស ព្រោះហេតុមិនចេះអៀនខ្មាស។ ការនិយាយដោយឥតអៀនខ្មាសនេះច្រើនតែនាំឱ្យថោកទាប នាំឱ្យខូចតម្លៃ

សម្តីរបស់ខ្លួនបើមិនច្រើនក៏តិច ឃើញថាជាទោសមួយក្នុងការនិយាយ ព្រោះហេតុនោះ កាលបើត្រូវការនិយាយឱ្យគេស្តាប់ ត្រូវពិនិត្យខ្លួនឯងទុកដាក់ឱ្យល្មមសិន គឺកុំអៀនខ្មាសពេក កុំឥតអៀនខ្មាសពេក។

ការប្រព្រឹត្តធ្វើដោយកាយក្តី វាចាក្តី ចិត្តក្តី ដែលឥតអៀនខ្មាសនោះច្រើនតែត្រឡប់ទៅជាទោសគួរឱ្យគេនិន្ទាពេបជ្រាយបានជាដរាប។

ការសម្តែងធម៌អាថ៌ឬប្រកាសសេចក្តីអំពីច្បាប់បញ្ញត្តិណាមួយ, បើនិយាយដោយប្រធាននៃការសម្តែងមាន២យ៉ាងគឺ និគ្គហមុខ=ការសម្តែងផ្ចាញ់ផ្ចាលជាប្រធាន១, បគ្គហមុខ =ការសម្តែងលើកសរសើរជាប្រធាន១។

ការសម្តែងប្រាប់ទោសអំពីសេចក្តីប្រព្រឹត្តខុស ចំពោះបុគ្គលអ្នកប្រព្រឹត្តខុស ហើយទាញឧទាហរណ៍អំពីការប្រព្រឹត្តត្រូវ ដើម្បីផ្ចាញ់ផ្ចាលសង្កត់សង្កិនដោយធម៌វិន័យ ឱ្យអ្នកស្តាប់ពិចារណារកហេតុផលខុសត្រូវឱ្យឃើញចំពោះខ្លួនឯង, ការសម្តែងដូច្នេះហៅថា "និគ្គហមុខ"។

ការសម្តែងប្រកាសគុណនៃសេចក្តីល្អ ដែលពួកអ្នកសប្បុរសបានប្រព្រឹត្តគោរពជឿកាន់ដោយត្រឹមត្រូវ ហើយទាញឧទាហរណ៍អំពីការប្រព្រឹត្តផ្សេងៗ ដើម្បីលើកសរសើរតាមធម៌វិន័យ, ដូច្នេះ ហៅថា "បគ្គហមុខ"។

ការសម្តែងនេះ ទុកជាមានច្រើនយ៉ាង ក៏គង់រួបរួមមកដោយខ្លីមានតែ២យ៉ាងប៉ុណ្ណោះ។ ការសម្តែងធម៌ឬសូត្របទធម៌ណាមួយដែលអាចធ្វើទៅបាន ក៏ព្រោះអាស្រ័យហេតុដែលឥតអៀនខ្មាសទើបប្រព្រឹត្តទៅបាន ប៉ុន្តែបើសម្តែងអាការវាតអាត ឥតក្រែងរអែង ឥតអៀនខ្មាសជ្រុលហួសពេក ក៏ត្រឡប់ទៅជាទោសដល់ខ្លួនដែលនាំឱ្យថោកឬក ខូចតម្លៃចរិយាធម៌របស់ខ្លួនជាប្រាកដ ដោយហេតុតែជួញនិយាយឥតអៀនខ្មាស។

សម្លេងខ្លាំង គឺសម្លេងលាន់ឮកងរំពង ជះចូលទៅប៉ះសោតប្បសាទនៃបុគ្គលដទៃ។ សម្លេងឮនេះជាសម្បត្តិដ៏ប្រសើររបស់អ្នកនិយាយ ដែលអាចនាំឱ្យអ្នកស្តាប់ចូលចិត្តស្តាប់ជាប់តទៅ បានយូរមិនធាប់ធុញទ្រាន់ ដោយហេតុថាមិនបាច់ផ្ទៀងត្រចៀកដោយផ្ចិតផ្ចង់ណាស់ក៏អាចឮច្បាស់បាន។ តែសម្លេងខ្លះគ្រាន់តែឮ

ខ្លាំង ប៉ុន្តែមិនពីរោះ។

សម្លេងពីរោះនេះរាប់ថាជាសម្បត្តិដ៏ល្អ, សូម្បីព្រះសម្មាសម្ពុទ្ធព្រះអង្គក៏មានលក្ខណៈដោយសម្លេងនេះដែរ។ បាលីថា "ព្រហ្មស្សរោ ភគវា" ប្រែថា "ព្រះដ៏មានបុណ្យ មានសម្លេងដូចជាសម្លេងនៃព្រហ្ម" សម្លេងពីរោះនេះជាលក្ខណៈល្អមួយរបស់ព្រះសម្មាសម្ពុទ្ធ។ សម្លេងពីរោះមានអង្គ៨ប្រការគឺៈ

១–វិស្សដ្ឋោ សម្លេងរលីងស្អាត,

២–វិញ្ញេយ្យោ សម្លេងច្បាស់លាស់ងាយយល់បាន,

៣–មញ្ជុ សម្លេងស្រទន់ពីរោះ,

៤–សវនីយោ សម្លេងគួរឱ្យចង់ស្តាប់,

៥–ពិន្ទុ សម្លេងត្រូវចំណុចចិត្តអ្នកស្តាប់,

៦–អវិសារី សម្លេងមិនព្រែក មិនបែក,

៧–គម្ភីរោ សម្លេងជ្រៅរំពងឮបានឆ្ងាយ,

៨–និន្នាទី សម្លេងបន្លឺមានទឹកដម។

គុណសម្បត្តិដោយសម្លេងដូចរៀបរាប់នេះ ជាការប្រសើរដោយឡែកដែរ។ តែបើអ្នកដែលគ្រាន់តែមានសម្លេងប៉ុណ្ណោះ ក៏មិនទាន់សម្រេចផលល្អនៅឡើយ ព្រោះថាសម្លេងនេះ គ្រាន់តែជាគ្រឿងឧបករណ៍នៃការសម្តែងប៉ុណ្ណោះ កាលបើគុណសម្បត្តិខាងដើមមិនមានទេឬការចេះដឹងមានតិចតួច មិនគ្រប់គ្រាន់ប្រើប្រាស់សម្លេងនោះឱ្យមានប្រយោជន៍មិនកើត មួយទៀត សម្លេងនេះបើខ្វះការចេះដឹង, ខ្វះសីលធម៌សណ្តាប់ធ្នាប់ ក៏យកជាការមិនបាន ព្រោះមិនទាន់គ្រប់លក្ខណៈនៃគុណសម្បត្តិនៅឡើយ។

គុណសម្បត្តិរបស់លោក-អ្នកទេសនាឬអ្នកនិយាយមាន៤យ៉ាង ដូចអធិប្បាយមកនេះ ជាគុណសម្បត្តិជាន់ទាបឬសាមញ្ញភាយរង មិនទាន់រាប់ថាជាគុណសម្បត្តិជាន់ខ្ពស់គ្រប់លក្ខណៈនៅឡើយ។

លោកអ្នកទេសនាឬអ្នកនិយាយការត្រូវមានគុណសម្បត្តិ៤យ៉ាងទៀត ទើបពេញទីជាគុណសម្បត្តិជាន់ខ្ពស់ដែលគួរសរសើរដោយពិត។

គុណសម្បត្តិជាន់ខ្ពស់នោះគឺ:

*១–ការចេះដឹងពាក្យពេចន៍ យល់កិច្ចការច្រើន ចាំគោលធម៌-ច្បាប់បានច្រើន,*

*២–មានបដិភាណ គឺប្រាជ្ញាវាងវៃប្រកបដោយសមត្ថភាព,*

*៣–មានសប្បុរិសធម៌៧ប្រការគ្រប់គ្រាន់,*

*៤–មានចិត្តបរិសុទ្ធ មិនញាប់ញ័រដោយលោកធម៌ពេក មិនប្រកបដោយអគតិ។*

*គុណសម្បត្តិសាមញ្ញខាងដើម៤យ៉ាង ព្រមទាំងគុណសម្បត្តិជាន់ខ្ពស់៤យ៉ាងនេះទៀតផ្សំបញ្ចូលគ្នាត្រូវជាគុណសម្បត្តិ៨យ៉ាង។ លោកអ្នកទេសនាឬអ្នកនិយាយការណាមួយក្នុងទីប្រជុំ កាលបើប្រកបដោយគុណសម្បត្តិ៨យ៉ាងដូចពោលមកនេះ ទើបចាត់ថាជាបុគ្គលប្រសើរបំផុតក្នុងចំណោមអ្នកសម្ដែងទាំងឡាយ។*

លោកអ្នកសម្ដែងត្រូវប្រកបដោយអង្គ៥យ៉ាងតទៅទៀតគឺ:

*១–សម្ដែងតាមលំដាប់លំដោយ មិនកាត់ មិនរំលងគោលសេចក្ដី,*

*២–សម្ដែងដោយអាងហេតុផល កុំឱ្យច្រឡំដោយធម្មាធិដ្ឋាននិងបុគ្គលាធិដ្ឋាន,*

*៣–សម្ដែងដោយមេត្តា ប្រាថ្នាឱ្យបានប្រយោជន៍ដល់អ្នកស្ដាប់,*

*៤–មិនត្រូវសម្ដែងដោយការសម្លឹងលាភសក្ការៈ,*

*៥–មិនត្រូវសម្ដែងដោយការលើកខ្លួន ហើយបន្តុះបង្អាប់អ្នកដទៃ គឺសម្ដែងឱ្យសមតាមធម៌ដែលពិតមែន ប្រកបដោយហេតុការជាក់លាក់។*

*គុណសម្បត្តិទាំងនេះជាការក្រណាស់, លោកអ្នកទេសនាឬអ្នកធ្វើសន្និសីទកម្រនឹងមានគុណសម្បត្តិទាំងនេះគ្រប់គ្រាន់ក្នុងខ្លួន ព្រោះហេតុនោះ បណ្ឌិតគប្បីសិក្សាហាត់រៀនអប់រំជាមុន។ វិធានការនៃកិច្ចសិក្សាដើម្បីឱ្យមានគុណសម្បត្តិទាំង៨យ៉ាងនេះ មិនមែនលើសវិស័យរបស់មនុស្សគ្រប់គ្នាទេ គឺអាចហាត់ពត់ចិត្តទូន្មានបង្វឹកឱ្យបានបទបែបនោះៗខ្លះមិនខាន បើទុកជាមាននិស្ស័យធម្មជាតិរឹងត្អឹងយ៉ាងណា ក៏មិនហួសអំពីការបង្វឹក ការទូន្មានដ៏ឧក្រិដ្ឋដែរ, បើទុកជាមិនបានគុណសម្បត្តិនោះគ្រប់គ្រាន់ក៏គង់បានខ្លះមិនខាន។*